# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**

លេខ : ១២៩/០០១/២០០៧

ចុះថ្ងៃទី ០២ ខែ មករា ឆ្នាំ២០០៧

**សេចក្តីសម្រេច**

លេខ : ០៩១/០០២/២០០៧ កបធ.ច

ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៧

## ក្រុមប្រឹក្សាធម្មនុញ្ញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៧/០៦ ចុះថ្ងៃទី២៦ ខែ ធ្នូ ឆ្នាំ១៩៩៧ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៩០២/០១៧ ចុះថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ២០០២ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៦/០១៩ ចុះថ្ងៃទី២៧ ខែ មិថុនាឆ្នាំ២០០៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្ម មាត្រា ១៣ ថ្មី នៃច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៤៧/០០២/២០០២ កបធ.ច ចុះថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ២០០២
- បានឃើញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ លេខ ០៧៩/០០៦/២០០៦ កបធ.ច ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ២០០៦
- បានឃើញលិខិតលេខ ០០១ រស ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ២០០៦ របស់ឯកឧត្តម **ខួន ញ៉ិល**

ប្រធានរដ្ឋសភាស្តីទី ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញបានទទួលនៅថ្ងៃទី ០២ ខែ មករា ឆ្នាំ ២០០៧ វេលាម៉ោង ១៥ និង ៣០ នាទី ។

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា រដ្ឋសភា និង ព្រឹទ្ធសភាបានអនុវត្តយ៉ាងត្រឹមត្រូវតាមបែបបទ ដែលមានចែងក្នុងមាត្រា ១១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ ក្នុងការពិនិត្យនិងអនុម័តច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ
- យល់ឃើញថា សំណើរបស់ឯកឧត្តម **ខួន ញឹល** ប្រធានរដ្ឋសភាស្តីទី ស្របនឹងមាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ។ ដូច្នេះ សំណើនេះ អាចទទួលយកមកពិនិត្យបាន
- យល់ឃើញថា ទម្រង់នៃការតាក់តែងច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានអ្វីខុសនឹងរដ្ឋធម្មនុញ្ញទេ
- យល់ឃើញថា មាត្រា ៣ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៣ ថ្មី ដោយលុបឃ្លា " ***នៅថ្ងៃអាទិត្យនៃសប្តាហ៍ទី៤ មុនដំណាច់ឆ្នាំទី៥នៃនីតិកាលរបស់រដ្ឋសភា*** " និងបន្ថែម " ***កាលបរិច្ឆេទនៃការបោះឆ្នោតត្រូវកំណត់ និង ប្រកាសដោយនាយករដ្ឋមន្ត្រីតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ*** " " ***ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រត្រូវធ្វើនៅថ្ងៃអាទិត្យតែមួយថ្ងៃ*** " និងយកឃ្លា " ***លើកលែងតែក្នុងស្ថានភាពណាមួយដូចខាងក្រោម*** " មកដាក់ក្នុងវាក្យខ័ណ្ឌថ្មីនេះ ។ បទបញ្ញត្តិដទៃទៀតត្រូវបានរក្សាខ្លឹមសារដើមទាំងស្រុង
- យល់ឃើញថា មាត្រា ៤៩ ថ្មី ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៤៩ ថ្មី (ពីរ) ដោយបន្ថែមមួយវាក្យខ័ណ្ឌ " ***នៅឆ្នាំដែលមានការបោះឆ្នោតជាសកល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចសម្រេចកាលបរិច្ឆេទ និង រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះបោះឆ្នោត និង ការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតផ្សេងពីនេះ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចបន្ថែមរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និង ការចុះឈ្មោះបោះឆ្នោតយ៉ាងយូរដប់ប្រាំ (១៥) ថ្ងៃ*** " បទបញ្ញត្តិឯទៀតរក្សាទុកដដែល
- យល់ឃើញថា មាត្រា ៧៣ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ៧៣ ថ្មី ដោយបន្ថែមមួយវាក្យខ័ណ្ឌ " **របៀបបែបបទប្តឹងជំទាស់ ឬ តវ៉ាក្នុងពេលឃោសនាបោះឆ្នោត និង ការដោះស្រាយពាក្យ**

**បណ្តឹងត្រូវកំណត់ដោយបទបញ្ជា និង នីតិវិធី ។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចសេចក្តីចុងក្រោយ "** ។ បទបញ្ញត្តិឯទៀតរក្សាទុកដដែល

- យល់ឃើញថា មាត្រា ១២០ ត្រូវបានធ្វើវិសោធនកម្មទៅជាមាត្រា ១២០ ថ្មី ដោយដកស្រង់ខ្លឹមសារពីមាត្រា ៣១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភាដោយគ្រាន់តែដូរពាក្យ ***"សមាជិកព្រឹទ្ធសភា"*** មក ***"សមាជិករដ្ឋសភា"*** វិញតែប៉ុណ្ណោះ
- យល់ឃើញថា បទបញ្ញត្តិទាំងអស់ក្នុងមាត្រាមួយ និង មាត្រាពីរនៃច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ពុំមានអ្វីមិនស្របនឹងរដ្ឋធម្មនុញ្ញនោះទេ ។

## សម្រេច

**មាត្រា ១.** ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តនៅថ្ងៃទី ១៥ ខែ ធ្នូ ឆ្នាំ ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ ហើយព្រឹទ្ធសភាក៏បានអនុម័តយល់ស្របតាមទម្រង់ និង គតិច្បាប់ទាំងស្រុង នៅថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ២០០៦ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ២ នីតិកាលទី ២ ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.** សេចក្តីសម្រេចនេះធ្វើនៅរាជធានីភ្នំពេញថ្ងៃទី ០៥ ខែ មករា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៧

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**